# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ ការព្យាបាលរោគផ្លូវចិត្ត (ត)

website ៖ www.hoksavann.org

ថ្ងៃទី៣ មករា ២០០៩



### ការព្យាបាលរោគផ្លូវចិត្ត
### តាមឧត្តមគតិព្រះពុទ្ធសាសនា

អ្នកសិក្សាព្រះពុទ្ធសាសនាបានដឹងហើយថា ព្រះពុទ្ធសាសនាដែលសំដែងឡើងដោយព្រះពុទ្ធជាម្ចាស់ បានសំដែងជាគោលសំខាន់ថា អ្វីទាំងអស់ទាំងមានវិញ្ញាណ ទាំងឥតវិញ្ញាណកើតមានតាមហេតុរបស់វា គឺហេតុផលឬកម្មផលតែងមានសម្ពន្ធភាពទាក់ទងគ្នា ។ បានសេចក្តីថា ហេតុមួយបានកើតឡើងតែងមានផលរបស់វា ឬកម្មមួយបានកើតឡើងតែងចេញជាផលមួយស្របតាមអំពើរបស់ខ្លួន ។ គេអាចពោលម៉្យាងទៀតថា ផលមួយបានកើតឡើង ដោយអាស្រ័យមានហេតុឬកម្មមួយបានកើតឡើង ។ ត្រង់នេះបញ្ជាក់ថា គ្មានផលណាមួយបានកើតឡើង ដោយគ្មានហេតុឬកម្មរបស់វាឡើយ ។ នេះជាច្បាប់ធម្មជាតិសកល សូម្បីក្រុមអ្នកសិក្សាស្រាវជ្រាវខាងវិទ្យាសាស្ត្រផ្នែករូប ក៏ទទួលស្គាល់សច្ចភាពដែលសំដែងឡើងដោយព្រះពុទ្ធជាម្ចាស់នេះដែរ ។ ធម្មជាតិទាំងនោះមានហេតុផលក្នុងខ្លួនរបស់វា ដូចពុទ្ធសាសនានិយាយអំពីហេតុផលរបស់ចិត្តចេតសិករូបនិព្វាន ឬដូចអ្នកប្រាជ្ញវិទ្យាសាស្ត្រនិយាយអំពីរូបវិទ្យានិងគីមីវិទ្យា ដែលវិភាគផ្នែករូប ក៏ឃើញមានហេតុផលក្នុងខ្លួនរបស់វា គ្មានព្រះជាម្ចាស់ណាបង្កើតឡើយ ។ ព្រះពុទ្ធជាម្ចាស់បានត្រាស់ដឹងការពិតនេះ ដែលហៅថាសង្ខារតាមរយៈវិបស្សនាវិជ្ជា ។

ការរៀបរាប់ខាងលើនេះបានបុចឲ្យយល់យ៉ាងច្បាស់ថា ការកើតទុក្ខ ឬការ

ព្រួយផ្លូវចិត្ត មកអំពីមានហេតុដែលនាំឲ្យព្រួយ ។ ដូចនេះដើម្បីរំលត់វិបត្តិផ្លូវចិត្តនេះ ត្រូវរំលត់ហេតុរបស់វា វិបត្តិផ្លូវចិត្តនោះក៏ត្រូវរលត់ ។ អ្នកប្រាជ្ញចិត្តវិទ្យាបច្ចុប្បន្ននេះមានដំណោះស្រាយវិបត្តិផ្លូវចិត្តនេះដែរ ប៉ុន្តែដោះស្រាយមិនចំបញ្ហា ឬមិនចំហេតុរបស់វា ដែលកើតឡើងឡើយ ដូចជាលួងលោមអ្នកមានវិបត្តិផ្លូវចិត្តឲ្យសប្បាយខាងផ្លូវកាមគុណរូបសម្លេងក្លិនរសសម្ផស្ស ឬដាក់ថ្នាំឲ្យដេកលក់ជាដើម ។ មុននឹងយល់អំពីដំណោះស្រាយវិបត្តិផ្លូវចិត្តរបស់មនុស្សតាមឧត្តមគតិព្រះពុទ្ធសាសនានេះ អ្នកសិក្សាគួរយល់អំពីតម្លៃនៃការត្រាស់ដឹងរបស់ព្រះពុទ្ធជាបន្តទៅទៀត ដោយយកន្លែងខ្លះប្រៀបមកវិទ្យាសាស្ត្រ ។

អ្នកសិក្សាខ្លះចង់ដឹងថា តើព្រះពុទ្ធត្រាស់ដឹងវិទ្យាសាស្ត្រឬទេ ? តើអ្វីជាវិទ្យាសាស្ត្រ ? វិទ្យាសាស្ត្រគឺជាក្បួនវិជ្ជាដែលរកឃើញការផ្សំធាតុផ្នែករូប តាមអាយតនៈធម្មតា ឬតាមប្រដាប់សំរាប់ពិសោធន៍ដូចរូបវិទ្យា និងគីមីវិទ្យាជាដើម ។ ចំណែកព្រះពុទ្ធជាម្ចាស់វិញ ទោះបីព្រះអង្គមិនបានសំដែងថា ធាតុនេះបើយកទៅផ្សំជាមួយធាតុនោះ នឹងកើតជាវត្ថុឈ្មោះនេះក៏ដោយ ក៏ព្រះអង្គបានសំដែងថា វត្ថុគ្រប់យ៉ាងកើតឡើងបីគ្រឿងផ្សំ (សង្ខារ) (Corps composé, component) ។ ព្រះពុទ្ធដីកាត្រង់ចំណុចនេះត្រូវចាត់ទុកថា ព្រះអង្គជាគ្រូវិទ្យាសាស្ត្រ ព្រោះអ្វី ? ព្រោះថា បើគេវិភាគតាមគីមីវិទ្យានិងរូបវិទ្យាទៅ គ្មានអ្វីកើតឡើងប្រាសចាកការរួមផ្សំធាតុឡើយ ។ ប៉ុន្តែមុខងារព្រះអង្គមិនសំដែងអំពីការបង្កើតសម្ភារៈឡើយ គឺព្រះអង្គសំដែងអំពីសេចក្តីទុក្ខ និងការចេញចាកទុក្ខ (និព្វាន) ដើម្បីរំដោះទុក្ខរបស់មនុស្សសត្វ ឬចេញផុតពីការកើតចាស់ឈឺស្លាប់ ។ ត្រឡប់មកប្រធានបទដើមវិញ រូបដែលមានរោគក្តី ចិត្តដែលមានរោគ (ទុក្ខផ្លូវចិត្ត) ក្តី គឺជាផលដែលកើតចេញមកអំពីហេតុដែលនាំឲ្យមានរោគ ។ បានសេចក្តីថា រូបដែលមានជម្ងឺ គឺបណ្តាលមកអំពីហេតុ ឬអំពើ (កម្ម) របស់ធាតុធ្វើការមិនតាមប្រក្រតី ដោយមានខូចអាការៈណាមួយ ឬបណ្តាលមកពីមេរោគណាមួយ ។ ឯចិត្តដែលសប្បាយនិងកើតទុក្ខ ក៏បណ្តាលមកអំពីហេតុ ឬអំពើ (កម្ម) របស់ចិត្តបានទទួលអារម្មណ៍ជាទីគាប់ចិត្ត ឬមិនគាប់ចិត្ត ។ ឧទាហរណ៍ សិស្សប្រឡងជាប់បានទទួលសញ្ញាប័ត្រ សិស្សនោះមានការសប្បាយរីករាយចិត្ត មកអំពីបានជោគជ័យពីការសិក្សា ។ ការប្រឡងជាប់ជាហេតុ ការសប្បាយចិត្តជាផល ។ ផ្ទុ

យទៅវិញ សិស្សកាលណាប្រឡងធ្លាក់តែងកើតទុក្ខ ។ ការប្រឡងធ្លាក់ជាហេតុ ការកើតទុក្ខជាផល ។ ហេតុអ្វីបានជាសិស្សនោះកើតទុក្ខ ព្រោះមកពីប្រឡងធ្លាក់ ។ ដំណោះស្រាយតាមមាគ៌ាព្រះពុទ្ធសាសនា ត្រូវឲ្យសិស្សពិចារណានូវភាពពុំទៀងនៃអ្វីទាំងអស់ កុំឲ្យមានការតូចចិត្ត ត្រូវខំប្រឹងប្រែងសិក្សាជាថ្មីទៀតនឹងបានជោគជ័យ គឺប្រឡងជាប់នៅពេលក្រោយទៀត ។ អ្នកប្រកបការងារចិញ្ចឹមជីវិត ដូចអ្នកធ្វើជំនួញជួញដូរផ្សេងៗ បើរកស៊ីចំណេញ ចិត្តតែងសប្បាយរីករាយ បើរកស៊ីខាត ចិត្តតែងកើតទុក្ខ ។ ដើម្បីបំបាត់ការកើតទុក្ខព្រោះរកស៊ីខាត ត្រូវរកមធ្យោបាយជាថ្មី ឬសិក្សាចំណេះបន្ថែមអំពីបច្ចេកទេសនៃការធ្វើជំនួញ ហើយប្រកបការងារបន្ត ទោះបីមានជោគជ័យក្តីមិនមានក្តីត្រូវលះបង់ការព្រួយចិត្ត ព្រោះមធ្យោបាយគ្រប់យ៉ាងបានប្រើហើយ ដោយពិចារណាឲ្យឃើញការពិតថា អ្វីទាំងអស់ក្នុងលោកពុំទៀង ត្រូវតែបន្តការងារដោយសេចក្តីសង្ឃឹម ។ បើរបស់បាត់ត្រូវស្វែងរក បើរកពុំឃើញទេ ត្រូវដកចិត្តពីការស្តាយរបស់នោះ ដោយពិចារណាថា របស់អ្វីក្នុងលោកមិនមានខ្លឹមសារ តែងតែបាត់បង់និងខូចខាតជាធម្មតា សូម្បីរូបរាងកាយរបស់ខ្លួនក៏ស្ថិតនៅក្នុងភាពពុំទៀងដូចគ្នា ។ បើក្រុមគ្រួសារមានម្តាយឪពុកកូនចៅមានជម្ងឺ ត្រូវនាំទៅមន្ទីរពេទ្យ ដើម្បីឲ្យពេទ្យព្យាបាល បើមានវិបត្តិផ្លូវចិត្ត ត្រូវបញ្ជូនឲ្យអ្នកជំនាញខាងចិត្តវិទ្យា ជាពិសេសអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាជួយពន្យល់ ឲ្យលះបង់នូវហេតុដែលនាំឲ្យមានវិបត្តិវិបត្តិផ្លូវចិត្តនោះ ។ បើមានវិបត្តិផ្លូវស្នេហា ត្រូវពិចារណាមើល តើគួរសម្រួលគ្នារស់នៅជាមួយគ្នាតទៅទៀតបានឬមិនបាន បើសម្រួលគ្នាអាចរស់នៅជាមួយគ្នាបាន ក៏សម្រួលគ្នាទៅ បើមើលឃើញថា ទោះបីសម្រួលគ្នាបាន ក៏មិនអាចរស់ជាមួយគ្នាបានយូរអង្វែងឡើយ ដោយសារទស្សនៈគំយោបល់និងការប្រព្រឹត្តផ្សេងគ្នា ក៏គួរចែកផ្លូវគ្នាដើរទៅ កុំឲ្យខូចផ្លូវចិត្ត ព្រោះតែជួបមុខគ្នារាល់ថ្ងៃហើយចិត្តមិនត្រូវគ្នា ។

(នៅមានត)

❄ ❄

❄